ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
~~~*~~~

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ទូរសារ / ទូរស័ព្ទ : (៨៥៥) ២៣ ២៧៧៥៨
លេខ: ៧៤៤ ប្រក.សហវ.ពដ

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦

# ប្រកាស

## ស្តីពី
## ការកំណត់មេគុណសំរាប់អនុវត្តក្នុងការទារ ប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

---x---

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា,
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤,
- បានឃើញព្រះរាជក្រឹត្យលេខ នស,រកត ១០៩៤,៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល,
- បានឃើញព្រះរាជក្រឹត្យលេខ នស,រកត ១០៩៤,៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល,
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦,
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១,នស,៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤,
- បានឃើញច្បាប់កែតំរូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស.រកម ០៩៩៥-០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥,
~~~

- បានឃើញអនុក្រឹត្យលេខ ៥៨អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់,
- បានឃើញប្រកាសលេខ ៣១៦ប្រក,សហវ,ពដ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់,
- បានឃើញសេចក្តីសំរេចលេខ ០១សសរ,ពដ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមបណ្តាខេត្ត-ក្រុង,
- បានឃើញប្រកាសលេខ ២២៤ប្រក,សហវ,ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីមិនបានប្រើប្រាស់ ។

## សំរេច

**ប្រការ១:** មេគុណសំរាប់វាយតំលៃលាភការប្រចាំខែ ដូចមានចែងក្នុងចំណុច២ និង ៣ ក្នុងប្រការ១ នៃប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានកំណត់ស្មើនឹង ០,០៨ ។

**ប្រការ២:** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល**

អគ្គលេខាធិការដ្ឋានរដ្ឋសភា
ទីស្តីការគណៈរដ្ឋមន្ត្រី
ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី២
គ្រប់ក្រសួង-ស្ថាប័នកណ្តាល
គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន"
គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"ដើម្បីមុខការ"

---

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
ឯកសារ-កាលប្បវត្តិ